# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**រដ្ឋសភា**

លេខ ...................... .រ.ស.

**<u>គោរពជូន</u>**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**
**នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា**

**<u>តាមរយៈ</u>** : សម្ដេចអគ្គមហាពញាចក្រី ហេង សំរិន ប្រធានរដ្ឋសភា

**<u>កម្មវត្ថុ</u>** : សំណើសុំសម្ដេចមេត្តាពិចារណាក្នុងការផ្លាស់ប្ដូរឯកឧត្តម ហោ **ណាំហុង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដើម្បីឲ្យការងារការទូតកម្ពុជាមានប្រៀបជាងប្រទេសថៃ ។

តបតាមកម្មវត្ថុខាងលើ យើងខ្ញុំសូមជម្រាបជូនសម្ដេចមេត្តាជ្រាបថា យើងខ្ញុំជាអ្នកតំណាងរាស្ត្រសង្កេតឃើញថា រយៈពេលជិត ០៣ឆ្នាំហើយ គិតចាប់តាំងពីការផ្ទុះអាវុធកាលពីថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៨ បញ្ហាប្រាសាទព្រះវិហារ នៅតែពុំទាន់ត្រូវបានដោះស្រាយឲ្យបានប្រសើរនៅឡើយ ។ ក្នុងរយៈពេលថ្មីៗនេះ ប្រទេសថៃនៅតែបន្តធ្វើការរំលោភឈ្លានពានមកលើបូរណភាពទឹកដី នៃព្រះរាជាណាចក្រកម្ពុជាដោយធ្វើការវាយប្រហារប្រដាប់អាវុធមកលើកងយោធពលខេមរភូមិន្ទ និងជនស៊ីវិលកម្ពុជានៅតាមព្រំដែនកម្ពុជា-ថៃ បើទោះជាមានការអន្តរាគមន៍ពីក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ និងសមាគមប្រជាជាតិអាស៊ី-អគ្នេយ៍ (អាស៊ាន) ស្នើសុំឲ្យមានការឈប់បាញ់គ្នាជាអចិន្ត្រៃយ៍ក៏ដោយ ។ ការរំលោភឈ្លានពានដោយប្រដាប់អាវុធរបស់ប្រទេសថៃ មកលើកម្ពុជាម្ដងហើយម្ដងទៀត មិនត្រូវបានសហគមន៍អន្តរជាតិថ្កោលទោស ឬចាត់វិធានការណាមួយចំពោះប្រទេសថៃនោះទេ ដោយគ្រាន់តែធ្វើការអំពាវនាវឲ្យភាគីទាំងពីរដោះស្រាយវិវាទនេះដោយសន្តិវិធី ។ ប្រការនេះបានបង្ហាញឲ្យឃើញយ៉ាងច្បាស់ពីការខ្វះសមត្ថភាព និងជំនាញពិតប្រាកដរបស់ប្រមុខការទូតកម្ពុជា គឺឯកឧត្តម ហោ **ណាំហុង** ក្នុងការស្វែងរកការគាំទ្រពីសហគមន៍អន្តរជាតិ ។ ប្រទេសកម្ពុជាមានសាលក្រម ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ១៩៦២ របស់តុលាការយុត្តិធម៌អន្តរជាតិ ទីក្រុងឡាអេ ដែលសម្រេចប្រគល់ប្រាសាទព្រះវិហារមកឲ្យកម្ពុជា ហើយនិងកិច្ចព្រមព្រៀងទីក្រុងប៉ារីស ឆ្នាំ១៩៩១ ដែលអាចធ្វើជាមូលដ្ឋានដ៏រឹងមាំសម្រាប់តទល់តាមផ្លូវច្បាប់ និងការទូតជាមួយប្រទេសថៃ ប៉ុន្តែដោយសារតែការងារទូតយើងខ្សោយ ធ្វើឲ្យប្រទេសកម្ពុជាចាញ់ប្រៀបប្រទេសថៃលើឆាកអន្តរជាតិ ។ ការចាញ់ប្រៀបនេះធ្វើអោយប៉ះពាល់យ៉ាងធ្ងន់ធ្ងរដល់កិត្យានុភាពរបស់ប្រទេសកម្ពុជា និងការដោះស្រាយជម្លោះព្រំដែនកម្ពុជា-ថៃពុំទទួលបានជោគជ័យលើឆាកអន្តរជាតិបានឆាប់រហ័សឡើយ ដែលទាមទារឲ្យមានការផ្លាស់ប្ដូរប្រមុខការទូតជាបន្ទាន់ ។

អាស្រ័យដូចបានជំរាបជូនខាងលើ សូមសម្ដេចអគ្គមហាសេនាបតីតេជោមេត្តាពិចារណាក្នុងការផ្លាស់ប្ដូរឯកឧត្តមឧបនាយករដ្ឋមន្ត្រី ហោ **ណាំហុង** ចេញពីតំណែងរដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយដាក់ជំនួសមកវិញនូវឥស្សរជនឆ្នើមណាម្នាក់ដែលមានសមត្ថភាព និងជំនាញពិតប្រាកដខាងការទូត ដើម្បីបញ្ឈប់ការរំលោភឈ្លានពានរបស់ប្រទេសថៃ និងធ្វើឲ្យបន្ទាត់ព្រំដែនកម្ពុជា-ថៃមានសន្តិភាពជាអចិន្ត្រៃយ៍ ដោយអនុគ្រោះ ។

សូមសម្ដេចមេត្តាទទួលនូវការគោរពរាប់អាន អំពីយើងខ្ញុំ ៕

*រាជធានីភ្នំពេញ, ថ្ងៃទី.០៤ ខែឧសភា ឆ្នាំ២០១១*

**បានឃើញ និងបញ្ជូនមក**
សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន
នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
"ដើម្បីពិនិត្យ" ។
ភ្នំពេញ, ថ្ងៃទី......... ខែ......... ឆ្នាំ២០១១
**ប្រធានរដ្ឋសភា**

**<u>ចម្លងជូន</u>** :
- ក្រសួងព្រះបរមរាជវាំង
- សម្ដេចអគ្គមហាធម្មពោធិសាល ជា ស៊ីម ប្រធានព្រឹទ្ធសភា
- អ្នកតំណាងរាស្ត្រ ចំនួន ១២ច្បាប់
- អគ្គលេខាធិការដ្ឋានរដ្ឋសភា "ដើម្បីជូនជ្រាប"
- ឯកសារ-កាលប្បវត្តិ